ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

លេខ: ០១៤ ...[illegible]

ទីក្រុងស្អាត ត្រូវតែផ្តើមចេញពីយើងទាំងអស់គ្នា

ថ្ងៃ ចន្ទ ៥រោច ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់អនុវត្តការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសមត្ថភាពផ្ទុកតាមគន្លងប្រក្រតីភាពថ្មី (Carrying Capacity Management System) សម្រាប់អាជីវកម្មហាង និងផ្សារ

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ក្រសួងទេសចរណ៍ មានកិត្តិយស សូមជម្រាបជូន រដ្ឋបាលរាជធានី ខេត្ត ភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ ម្ចាស់អាជីវកម្មហាង និងម្ចាស់/អ្នកគ្រប់គ្រងអាជីវកម្មផ្សារទំនើបខ្នាតធំ ផ្សារទំនើបខ្នាតតូច និងផ្សារសាធារណៈទាំងអស់ ឱ្យបានជ្រាបថា ដើម្បីអនុវត្តតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ២០២២ ស្តីពីការចូលរួមទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ (អូមីក្រុង) នៅក្នុងសហគមន៍ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ក្រសួងទេសចរណ៍ សូមធ្វើការណែនាំរដ្ឋបាលរាជធានី ខេត្ត បន្តជំរុញ និងពង្រឹងការអនុវត្តវិធានការ "**៣ការពារ ៣កុំ**" ការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងការអនុវត្តនីតិវិធីស្តង់ដាអប្បបរមា (SOP) តាមគន្លងប្រក្រតីភាពថ្មី ព្រមទាំងណែនាំម្ចាស់អាជីវកម្មហាង និងម្ចាស់/អ្នកគ្រប់គ្រងអាជីវកម្មផ្សារទំនើបខ្នាតធំ ផ្សារទំនើបខ្នាតតូច និងផ្សារសាធារណៈទាំងអស់ឱ្យប្រើប្រាស់**ប្រព័ន្ធគ្រប់គ្រងសមត្ថភាពផ្ទុកតាមគន្លងប្រក្រតីភាពថ្មី** (Carrying Capacity Management System)។ ក្នុងន័យនេះ ម្ចាស់អាជីវកម្មហាង និងម្ចាស់/អ្នកគ្រប់គ្រងអាជីវកម្មផ្សារទំនើបខ្នាតធំ ផ្សារទំនើបខ្នាតតូច និងផ្សារសាធារណៈទាំងអស់ត្រូវចូលរួមអនុវត្តការប្រើប្រាស់**ប្រព័ន្ធគ្រប់គ្រងសមត្ថភាពផ្ទុកតាមគន្លងប្រក្រតីភាពថ្មី** (Carrying Capacity Management System) តាមរយៈ**គេហទំព័រ** www.camccms.org ឬស្កេន QR code *(ដែលមានភ្ជាប់ដូចខាងក្រោម)* ប្រកបដោយស្មារតីទទួលខុសត្រូវ និងប្រសិទ្ធភាពខ្ពស់។

ទទួលបានសេចក្តីជូនដំណឹងនេះ សូម **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត** ភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ ម្ចាស់អាជីវកម្មហាង និងម្ចាស់/អ្នកគ្រប់គ្រងអាជីវកម្មផ្សារទំនើបខ្នាតធំ ផ្សារទំនើបខ្នាតតូច និងផ្សារសាធារណៈទាំងអស់ ចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**រដ្ឋមន្ត្រី**

**ថោង ខុន**

ស្កេន QR Code